អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន

## ប្រជាជន ៣០០នាក់ នៅស្រុកអន្លង់វែង នឹងមកធ្វើទស្សនកិច្ចសិក្សា នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងគុកទួលស្លែង

ប្រជាជន ៣០០នាក់ នៅស្រុកអន្លង់វែងនឹងមកធ្វើទស្សនកិច្ចសិក្សានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) និងនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង នៅថ្ងៃព្រហស្បតិ៍ ទី៩ ខែធ្នូ ឆ្នាំ២០១០នេះ។ ស្រុកអន្លង់វែងគឺជាទីតាំងចុងក្រោយបំផុតដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមមុនពេលធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជានៅខែមេសា ឆ្នាំ១៩៩៨។

នៅល្ងាចថ្ងៃពុធ ទី៨ ខែធ្នូ អ.វ.ត.ក. សហការជាមួយមជ្ឈមណ្ឌលបូផាណា នឹងរៀបចំបញ្ចាំងខ្សែភាពយន្តជាសាធារណៈនៅសាលាស្រុកអន្លង់វែង ស្តីអំពីសំណុំរឿងក្តីលេខ០០១។ បន្ទាប់ពីទស្សនាខ្សែភាពយន្តចប់ អ្នកចូលរួមនឹងចេញដំណើរទាំងយប់តាមរថយន្តក្រុង និងមកដល់គុកទួលស្លែងនិង អ.វ.ត.ក. នៅវេលាព្រឹកថ្ងៃព្រហស្បតិ៍។

ដំណើរទស្សនកិច្ចសិក្សានេះរៀបចំដោយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក. និងជាផ្នែកមួយនៃកម្មវិធីផ្សព្វផ្សាយព័ត៌មានទូទាំងប្រទេស ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនកម្ពុជាអំពីការងាររបស់ អ.វ.ត.ក.។ មានប្រជាជនកម្ពុជាជិត ៣ម៉ឺននាក់ មកពីទូទាំងប្រទេសបានចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សាក្នុងឆ្នាំ២០១០នេះ។

ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក. មានលទ្ធភាពផ្តល់មធ្យោបាយធ្វើដំណើរដល់អ្នកសារព័ត៌មានមួយចំនួន ដើម្បីធ្វើដំណើរពីភ្នំពេញទៅអន្លង់វែងនៅព្រឹកថ្ងៃពុធ ទី៨ ខែធ្នូ (លេខទូរស័ព្ទសម្រាប់ទាក់ទងព័ត៌មានបន្ថែមមាននៅខាងក្រោមនេះ)។ នៅពេលវិលត្រឡប់មកទីក្រុងភ្នំពេញវិញនៅយប់ថ្ងៃដដែលនោះ អ្នកសារព័ត៌មានអាចជិះរថយន្តក្រុងជាមួយអ្នកចូលរួមមកពីស្រុកអន្លង់វែង។

**កាលវិភាគ**

*ថ្ងៃពុធ ទី៨ ខែធ្នូ ឆ្នាំ២០១០*

ម៉ោង ០៦:៣០ ចេញដំណើរពីភ្នំពេញ

ម៉ោង ១៥:០០ ទៅដល់អន្លង់វែង

ម៉ោង ១៨:០០ បញ្ចាំងខ្សែភាពយន្តនៅទីរួមស្រុកអន្លង់វែង

ម៉ោង ២៣:០០ រថយន្តក្រុងចំនួន៦ ដឹកមនុស្សប្រមាណ៣០០នាក់ ចេញដំណើរពីអន្លង់វែងមកភ្នំពេញ

*ថ្ងៃព្រហស្បតិ៍ ទី៩ ខែធ្នូ ឆ្នាំ២០១០*

ម៉ោង ០៨:០០ មកដល់សារមន្ទីរទួលស្លែង និងមានមគ្គុទ្ទេសក៍នាំដើរមើល

ម៉ោង ១០:៣០ ទទួលទានអាហារថ្ងៃត្រង់នៅ អ.វ.ត.ក.

ម៉ោង ១១:០០ បទឧទ្ទេសនាមរបស់មន្ត្រីនៅ អ.វ.ត.ក. អំពីអាណត្តិនិងភារកិច្ចរបស់ អ.វ.ត.ក. និងមានកម្មវិធីសំណួរ-ចម្លើយ។

តំណាងសារព័ត៌មានដែលមានបំណងចូលរួមក្នុងកម្មវិធីនេះ សូមទាក់ទងលោក ឡាស អូលសិន តាមទូរស័ព្ទលេខ ០១២៤៨៨ ០២៣ ឬលោក ឌឹម សុវណ្ណារុំ ទូរស័ព្ទលេខ ០១២ ៨៨៨ ០៩៤។